**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**លេខ :** ០៥៥/២១ **ក.ប/ស.ជ.ណ.អ.ម.វ**

# សេចក្តីជូនដំណឹង

## ស្តីពី

## ការដាក់ឱ្យដំណើរការជាផ្លូវការនូវប្រព័ន្ធជាតិអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈពីចម្ងាយ ឬតាមអនឡាញ (National TVET E-Learning Platform)

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានកិត្តិយសសូមជម្រាបជូនដល់ សិក្ខាកាម សិស្ស និស្សិត អាណាព្យាបាល និងសាធារណជនទាំងអស់ មេត្តាជ្រាបថា ក្រសួងបានអភិវឌ្ឍប្រព័ន្ធជាតិអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈពីចម្ងាយ ឬតាមអនឡាញ (National TVET E-Learning Platform) ដែលប្រើប្រាស់បានទាំងនៅលើកុំព្យូទ័រ ថេប្លេត និងទូរស័ព្ទដៃឆ្លាតវៃ ដោយមានការគាំទ្រពីទីភ្នាក់ងារស្វីសសម្រាប់ការអភិវឌ្ឍ និងកិច្ចសហប្រតិបត្តិការ។ ប្រព័ន្ធជាតិនេះ ត្រូវបានបង្កើតឡើងដើម្បីចូលរួមដោះស្រាយការបង្រៀន និងរៀនពីចម្ងាយ ឬតាមអនឡាញរបស់សាស្ត្រាចារ្យ គ្រូបច្ចេកទេស និងសិក្ខាកាម សិស្ស និស្សិតក្នុងអំឡុងពេលនៃការរីករាលដាលជាសកលជំងឺកូវីដ-១៩ ក៏ដូចជាបានបើកច្រកសិក្សាថ្មីបន្ថែមមួយទៀតនៅក្នុងវិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ។ ប្រព័ន្ធជាតិនេះ មានមាតិកាមេរៀន វីដេអូបង្រៀន ឯកសារមេរៀនអេឡិចត្រូនិក ការស្វ័យវាយតម្លៃការសិក្សា ចំណេះដឹងទូទៅ និងព័ត៌មានផ្សេងៗពាក់ព័ន្ធទៅនឹងការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈនៅកម្ពុជា។ សិក្ខាកាម សិស្ស និស្សិត អាណាព្យាបាល និងសាធារណជនទាំងអស់ អាចចូលទាញយកប្រើប្រាស់កម្មវិធីនេះដែលមានឈ្មោះថា TVET E-Learning ពី Play Store, AppStore និង AppGallery ឬចូលទៅកាន់គេហទំព័រ www.tvet-elearning.com ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម សិក្ខាកាម សិស្ស និស្សិត អាណាព្យាបាល និងសាធារណជនទាំងអស់ ជ្រាបជាព័ត៌មាន។

ថ្ងៃ អង្គារ ៤រោច ខែ កត្តិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ២០២១

**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**

**ព័ត៌មានបន្ថែមសូមទំនាក់ទំនង៖**
០៩៦ ៧៧៧ ៨៩៧៥